**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ត.ក

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តី នួន ជា

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ២០១៤

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 01-Sep-2014, 09:45
CMS/CFO: Sann Rada

ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើសុំឲ្យទទួល និងពិចារណានៅលើភស្តុតាងបន្ថែមទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០១**

---

**ដាក់ដោយ៖**

**ក្រុមមេធាវីការពារក្តី នួន ជា៖**

សុន អរុណ

Victor KOPPE

ព្រុំ ផល្លា

សួន វិសាល

លីវ សុវណ្ណា

Joshua ROSENSWEIG

Doreen CHEN

Xiaoyang NIE

**ចម្លងជូន៖**

**សហជនជាប់ចោទ**

**សហព្រះរាជអាជ្ញា៖**

ជា លាង

Nicholas KOUMJIAN

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ

Marie GUIRAUD

អនុលោមតាមវិធាន ១០៤(១) និង ១០៨(៧) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក (វិធានផ្ទៃក្នុង) សហមេធាវីការពារក្តី នួន ជា ("ក្រុមមេធាវីការពារក្តី") សូមដាក់សំណើនេះ សុំឱ្យទទួល និងពិចារណាទៅលើភស្តុតាងបន្ថែម ("សំណើសុំឱ្យពិចារណាទៅលើភស្តុតាងបន្ថែម") ទាក់ទងនឹងបណ្តឹងសាទុក្ខដែលគ្រោងនឹងដាក់ប្តឹងនាពេលឆាប់ៗខាងមុខប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០១។

## I. ប្រវត្តិនីតិវិធី

1. នៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១១ ក្រុមមេធាវីការពារក្តី នួន ជា បានដាក់បញ្ជីបឋមស្តីពីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវកោះហៅឱ្យមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។ បញ្ជីនេះរួមមាន ថេត សម្បត្តិ និង Rob Lemkin ដែលជាសហប្រធាន និងជាសហផលិតករនៃខ្សែភាពយន្តចំនួនពីរ ដែលមាននៅក្នុងសំណុំរឿង គឺរឿង *សត្រូវប្រជាជន* និង *មួយថ្ងៃនៅទួលពោធិ៍ជ្រៃ*[1]។

2. នៅថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០១៣ ក្រុមមេធាវីការពារក្តីបានទទួលអ៊ីមែលមួយដែល Lemkin បានផ្ញើមកមេធាវី ដោយមេធាវីមិនបានសរសេរទាក់ទងគាត់ ("អ៊ីមែលរបស់ Lemkin")។ អ៊ីមែលនេះបានសង្ខេបអំពីសម្ភារ/ឯកសារមួយចំនួនដែល Lemkin រួមជាមួយនិង ថេត សម្បត្តិ ទទួលបាន។ អ៊ីមែលរបស់ Lemkin បានបញ្ជាក់*ក្នុងចំណោមចំណុចនានា* ថា យោងតាមភស្តុតាងដែលពួកគេប្រមូលបាន ឧក្រិដ្ឋកម្មនានាដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តឡើងនៅទួលពោធិ៍ ជ្រៃ ត្រូវបានធ្វើឡើង "ក្រោមបញ្ជារបស់ រស់ ញឹម ពុំមែនក្រោមបញ្ជារបស់មជ្ឈិមបក្សឡើយ"។ គាត់បានបន្ថែមទៀតថា គាត់ និង ថេត សម្បត្តិ បាន"ប្រមូលភស្តុតាងជាច្រើនអំពីផែនការរបស់ រស់ ញឹម"[2]។ នៅព្រឹកថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៣ និងនៅក្នុងសំណើជាលាយលក្ខណ៍អក្សរក្រោយៗមកទៀត ក្រុមមេធាវីការពារក្តីបានស្នើសុំឱ្យទទួលយកអ៊ីមែលនេះមកធ្វើជាភស្តុតាង ដោយអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ព្រមទាំងស្នើសុំឱ្យកោះហៅ Lemkin មកធ្វើជាសាក្សី និងបើកការស៊ើបអង្កេតអនុលោមតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង ទៅលើសម្ភារ/ឯកសារដែល Lemkin មាន[3]។

---

[1] ឯកសារ E9/4/4.4 "ឧបសម្ព័ន្ធ ក-បញ្ជីឈ្មោះសាក្សី" ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ លេខរៀង ២៥៣ ៤៥៦។

[2] ឯកសារ E294 "សំណើសុំទទួលយកភស្តុតាងថ្មី កោះហៅ Rob Lemkin និងចាប់ផ្តើមការស៊ើបអង្កេត" ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៣ កថាខណ្ឌ ២។

[3] ឯកសារ E1/221.1 "ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ" ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ ៧:៤៩-១០:១៨។ ឯកសារ E294 "សំណើសុំទទួលយកភស្តុតាងថ្មី កោះហៅ Rob Lemkin និងចាប់ផ្តើមការស៊ើបអង្កេត" ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៣ (ភាសាអង់គ្លេស)។

3. សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី បានជំទាស់ទៅនឹងសំណើសុំស្នើរតែទាំងអស់។ សហព្រះរាជអាជ្ញាបានចោទសួរដដែលៗអំពីការយល់ដឹងរបស់ Lemkin អំពីបក្សកុម្មុយនីស្តកម្ពុជា និងអំពីខ្សែវីដេអូដែលគាត់ និង ថេត សម្បត្តិ បានទទួល[4]។ សហព្រះរាជអាជ្ញាបានផ្តល់ទឡ្ហីករណ៍ថា ការងារស្រាវជ្រាវដល់កន្លែងត្រូវបាន "ដឹកនាំដោយ" ថេត សម្បត្តិ ដែលបាន"ធ្វើការងារទាំងនេះអស់រយៈពេល ៦ ឬ ៧ ឆ្នាំ" មុនពេល Lemkin ចូលរួមក្នុងការងារទាំងនេះ រួមទាំងការស៊ើបអង្កេត "ជាច្រើនឆ្នាំ" ទៅលើហេតុការណ៍នានានៅទួលពោធិ៍ជ្រៃផងដែរ[5]។

4. អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា អ៊ីមែលរបស់ Lemkin ត្រូវបានទទួលយកមកដាក់បញ្ចូលនៅក្នុងកំណត់ត្រារួចហើយក្រោយពីបានអាននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ហើយតម្លៃជាភស្តុតាងនៃអ៊ីមែលនេះ "គឺជាបញ្ហាមួយដែលស្ថិតនៅក្នុងអំណាចឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះ"[6]។ អង្គជំនុំជម្រះបានបដិសេធសំណើសុំកោះហៅ Lemkin ឬ បើកការស៊ើបអង្កេតលើភស្តុតាងដែលគាត់មាន។ អង្គជំនុំជម្រះបានសម្រេច *ក្នុងចំណោមចំណុចនានា* ថា Lemkin "និយាយភាសាខ្មែរបន្តិចបន្តួច ហើយភាគច្រើនលោកមិនបានចូលរួមនៅក្នុងកិច្ចសម្ភាសន៍ជាមួយនឹងជនជាប់ចោទនោះទេ"[7]។ អង្គជំនុំជម្រះបានបញ្ជាក់បន្ថែមទៀតថា ថេត សម្បត្តិ "ដែលជាអ្នកនិយាយភាសាខ្មែរជាភាសាកំណើត និងជាបុគ្គលដែលបានដឹកនាំកិច្ចសម្ភាសន៍ទាំងឡាយជាមួយនឹងជនជាប់ចោទ នួន ជា គឺល្អបំផុតដែលត្រូវដាក់ជំនួសដើម្បីផ្តល់សេចក្តីពិស្តារស្តីពីឃ្លុតខ្សែភាពយន្តបន្ថែម ដែលគ្មាននៅក្នុងខ្សែភាពយន្តណាមួយនៅក្នុងសំណុំរឿង"[8]។

5. នៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានបញ្ចប់សវនាការដេញដោលលើភស្តុតាងនៅក្នុងសំណុំរឿង ០០២/០១ ដោយនៅថ្ងៃនោះបានបើកសវនាការចុងក្រោយឱ្យផ្តល់ទឡ្ហីករណ៍ផ្ទាល់មាត់។ នៅថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានប្រកាស សាល

---

[4] ឯកសារ E1/223.1 "ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ" ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ ១១២:៧-១១៧:៥ (ភាសាអង់គ្លេស)។

[5] ឯកសារ E1/223.1 "ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ" ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ ១១៣:១, ១១៥:១០, ១១៦:១១-១២។

[6] ឯកសារ E294/1 "សេចក្តីសម្រេចលើសំណើរបស់ នួន ជា ស្នើសុំឱ្យទទួលយកភស្តុតាងថ្មី ឱ្យចាប់ផ្តើមការស៊ើបអង្កេត និងឱ្យកោះហៅលោក Rob Lemkin" កថាខណ្ឌ ១៣។

[7] ឯកសារ E294/1 "សេចក្តីសម្រេចលើសំណើរបស់ នួន ជា ស្នើសុំឱ្យទទួលយកភស្តុតាងថ្មី ឱ្យចាប់ផ្តើមការស៊ើបអង្កេត និងឱ្យកោះហៅលោក Rob Lemkin" កថាខណ្ឌ ១៦។

[8] ឯកសារ E294/1 "សេចក្តីសម្រេចលើសំណើរបស់ នួន ជា ស្នើសុំឱ្យទទួលយកភស្តុតាងថ្មី ឱ្យចាប់ផ្តើមការស៊ើបអង្កេត និងឱ្យកោះហៅលោក Rob Lemkin" កថាខណ្ឌ ១៤។

ក្រុមរបស់ខ្លួននៅក្នុងសំណុំរឿង ០០២/០១ ដោយបានផ្តន្ទាទោស នួន ជា និង ខៀវ សំផន ចំពោះ បទឧក្រិដ្ឋទាំងអស់ដែលត្រូវបានចោទប្រកាន់ ហើយបានសម្រេចដាក់ទោសជនជាប់ចោទម្នាក់ៗឱ្យជាប់ពន្ធនាគារអស់មួយជីវិត ("សាលក្រមសំណុំរឿង ០០២/០១")[9]។ នៅក្នុងថ្ងៃប្រកាសសាលក្រមនោះផងដែរ អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចស្តាពរលើឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដែលត្រូវបានស្នើសុំឱ្យមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ("សេចក្តីសម្រេចស្តាពរអំពីឈ្មោះសាក្សី")[10]។ សាលក្រមសំណុំរឿង ០០២/០១ មិនបានយោងទៅអ៊ីមែលរបស់ Lemkin នោះទេ ប៉ុន្តែបានយោងយ៉ាងច្រើនលើខ្សែភាពយន្តឯកសារផលិត "ដោយ ថេត សម្បត្តិ និង R. Lemkin" យកមកធ្វើជាភស្តុតាងដាក់បន្ទុក[11]។ សេចក្តីសម្រេចស្តាពរអំពី ឈ្មោះសាក្សី មិនបានផ្តល់មូលដ្ឋានបន្ថែមចំពោះសេចក្តីសម្រេចមិនកោះហៅ Lemkin ឬ មិនបើកការស៊ើបអង្កេតនោះឡើយ[12]។

## II. ភស្តុតាងបន្ថែម

6. នៅថ្ងៃទី ១២ និងថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៤ ថេត សម្បត្តិ បានផ្តល់កិច្ចសម្ភាសន៍មួយ ដែលមានចំនួនពីរភាគ ជាមួយវិទ្យុវីអូអេជាភាសាខ្មែរ ("កិច្ចសម្ភាសន៍")។ ក្រុមមេធាវីការពារក្តីស្នើសុំឱ្យទទួលយកខ្សែអាត់ថតសម្លេងទាំងស្រុងនៃកិច្ចសម្ភាសន៍នេះ ដែលត្រូវបានដាក់បញ្ចូលបន្ថែមទៅក្នុងប្រព័ន្ធផ្ទុកឯកសាររួម (Shared Materials Drive) រួចហើយនោះ។ ខាងក្រោមនេះជាប្រតិចារឹក នៃកិច្ចសម្ភាសន៍ ដែលក្រុមមេធាវីការពារក្តី នួន ជា បានធ្វើដោយដកស្រង់កិច្ចសម្ភាសន៍ទាំងស្រុង[13]។

<u>ភាគទី I: ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៤</u>

សេង ៖ បាទ! សូមជម្រាបសួរលោក ថេត សម្បត្តិ។

---

[9] ឯកសារ E313 "សាលក្រមសំណុំរឿង ០០២/០១" ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ ("សាលក្រមសំណុំរឿង ០០២/០១")។

[10] ឯកសារ E312 "សេចក្តីសម្រេចស្តាពរស្តីពីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវស្តាប់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១" ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ ("សេចក្តីសម្រេចស្តាពរស្តីពីសាក្សី")។

[11] *សូមមើល* សាលក្រមសំណុំរឿង ០០២/០១ លេខយោងជើងទំព័រ ៩៧០ ១៥១០ ២០៩៤ ២០៩៦ ២១១១ ២១១៦ ២១១៩ ២១២២ ២១២៦ ២១៣៣ ២១៣៤ ២១៣៥ ២១៣៦ ២៥៩៧។

[12] *សូមមើល* សេចក្តីសម្រេចស្តាពរស្តីពីសាក្សី។

[13] ក្រុមមេធាវីការពារក្តីស្នើសុំប្រតិចារឹកផ្លូវការមួយពីអង្គភាពប្រតិចារឹក ប៉ុន្តែសំណើសុំនេះត្រូវបានបដិសេធដោយផ្អែកលើមូលហេតុថា ប្រតិចារឹកនេះពុំទាន់មាននៅក្នុងសំណុំរឿងនៅឡើយ។

សម្បត្តិ ៖ បាទ! សូមជម្រាបសួរលោក គឹមសេង។

សេង ៖ បាទ! នៅថ្ងៃទីប្រាំពីរខែសីហា គឺលោក នួន ជា និង ខៀវ សំផន ត្រូវបានសាលាក្តីខ្មែរក្រហមហ្នឹង កាត់ទោសឲ្យជាប់ពន្ធនាគារមួយជីវិត តើការកាត់នេះសមនឹងការទទួលខុសត្រូវរបស់គាត់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ? ហើយអឺ... នៅក្នុងនាមលោកជាអ្នកដែលបានស្រាវជ្រាវនិងជួបសម្ភាសន៍ជាមួយនឹងលោក នួន ជា ជាច្រើនឆ្នាំនោះបាទ។

សម្បត្តិ ៖ ចំពោះខ្ញុំ ខ្ញុំមិន...មិនវិនិច្ឆ័យចំពោះការ សាលក្រមដែលថា ដាក់ទោសគាត់ប៉ុន្មានឆ្នាំមួយជីវិតអីយ៉ាងណានោះ។ ខ្ញុំអត់ចាប់អារម្មណ៍ចំពោះចំណុចហ្នឹងទេ។ ព្រោះ ហេតុអ្វី?

សេង ៖ បាំ! ហេតុអ្វីទៅបាំ?

សម្បត្តិ ៖ បាំ! មូលហេតុដែលថា ខ្ញុំមិន...មិនចាប់អារម្មណ៍ចំពោះហ្នឹងដោយសារថាអ្វីដែលខ្ញុំស្រាវជ្រាវរកឃើញ វាខុសពីអ្វីដែលតុលាការបានរកឃើញ។ ព្រោះជនដែលផ្តួចផ្តើមគំនិតបង្អត់បាយប្រជាជន ចាប់ចងប្រជាជន សម្លាប់ប្រជាជន ជនទាំងអស់នោះនៅរស់មានសេរីភាព។ ដូច្នេះហើយបានខ្ញុំនិយាយថា ការកាត់ក្តីចំពោះលោក នួន ជា និងលោក ខៀវ សំផន អ្នកណាក៏ដោយ ខ្ញុំចាត់ទុកថា អត់មានយុត្តិធម៌ទេ។ ហ្នឹងហើយមូលហេតុដែលថាមិនមានយុត្តិធម៌គឺដោយសារថា ជនដែលផ្តួចផ្តើមគំនិត បង្អត់បាយប្រជាជន ចាប់ចងប្រជាជន សម្លាប់ប្រជាជន ជនទាំងអស់នោះនៅរស់ដោយមានសេរីភាព។ ក្រុមនោះបានធ្វើឲ្យរបបរបស់លោក នួន ជា ឬ ប៉ុល ពត ហ្នឹង ធ្វើឲ្យមាន ទៅជាមានការបង្អត់បាយចាប់ចង កាប់សម្លាប់ ដូច្នេះខ្ញុំរកឃើញចំណុចអស់នេះ ហើយអ្នកអស់ហ្នឹងកំពុងរស់នៅ

សេង៖ បាទ!

សម្បត្តិ៖ អ្នកអស់ហ្នឹងកំពុងសារភាពចំពោះអ្វីដែលគាត់បានធ្វើពីសម័យនោះ។ ហ្នឹងហើយបានខ្ញុំនិយាយថា ការកាត់ក្តីមិនទាន់មានយុត្តិធម៌ទេ។ ចឹងហើយបានថា ចំពោះខ្លួនខ្ញុំផ្ទាល់ខ្ញុំទទួលបាននូវការផ្សះផ្សាក្នុងខ្លួនខ្ញុំ ដោយសារថា ខ្ញុំបានដឹងការពិត។ ប៉ុន្តែក្នុងតុលាការយើង ខ្ញុំឃើញថា តុលាការគាត់រកអត់ឃើញ។

សេង៖ បាទ!

សម្បត្តិ៖ គាត់រកអត់ឃើញចំណុចហ្នឹងផង គាត់រកឃើញតែមនុស្សប៉ុន្មាននាក់ថ្នាក់កំពូល យើងដឹងហើយថ្នាក់កំពូលទោះបីត្រូវឬក៏ខុសក៏ដោយ អ្នកឯងត្រូវតែទទួលខុសត្រូវ។ ទោះបីមិនបានធ្វើឬបានធ្វើក៏ដោយ ប៉ុន្តែយើងជាថ្នាក់មេដឹកនាំ ចឹងហ៎ាស! ដូច្នេះយើងត្រូវតែទទួល។ ប៉ុន្តែកំរិតថាទោសប៉ុនណាអាហ្នឹងខ្ញុំមិននិយាយទេបាទ។

សេង ៖ បាទ! ការលើកឡើងរបស់លោក ក៏ដូចជាអ្នកវិភាគ និងអ្នកច្បាប់មួយចំនួនបានលើកឡើងថា បើគេមិនយក ដូចថាការទទួលខុសត្រូវឧក្រិដ្ឋកម្មរួមមកកាត់ទោសទេ គឺពិបាកនឹងការដាក់ទោសមេខ្មែរក្រហមទាំងពីរនាក់នេះណាស់។ លោកបាននិយាយបន្តិចអម្បាញ់មិញទាក់ទងនឹងអ្នកដែលធ្វើឲ្យរបបហ្នឹងខុសពីគោលការណ៍ដើម។ តើលោកអាចបញ្ជាក់បន្ថែមបានទេថាតើ នួន ជា ហើយនិង ខៀវ សំផនហ្នឹង មានការទទួលខុសត្រូវកំរិតណាដែរបាទ! ក្នុងរបបគាត់នោះបាទ?

សម្បត្តិ ៖ អឺ... ខ្ញុំនិយាយចំពោះលោក នួន ជា គាត់ជាថ្នាក់កំពូលជាមួយនិងលោក ប៉ុល ពត។ អញ្ចឹងទោះបីថា កំរិតណាក៏ដោយក៏គាត់ត្រូវមាន ទទួលកំហុស ត្រូវមានការទទួលទោស។ ប៉ុន្តែគ្រាន់តែថា កំរិតណាមួយឲ្យមានការសមស្រប។ អញ្ចឹងដើម្បីឲ្យគាត់ទទួលទោសឲ្យបានសមស្របទាល់តែតុលាការហ្នឹងរកឃើញការពិត ទាល់តែរកឃើញជនដែលដល់ អ្នកដែលប្រព្រឹត្តរបប ដែលធ្វើឲ្យ សូម្បីតែ ប៉ុល ពត នួន ជា គាត់ឈឺក្បាលណាស់។ ប៉ា! ខ្ញុំនិយាយត្រង់ម៉ង ខ្ញុំនឹងនិយាយថា ខ្ញុំនិង នួន ជា អារម្មណ៍ សឹងតែមនុស្សតែមួយហើយខ្ញុំនិយាយប៉ុនណ្ណឹង ទោះបីថាខ្ញុំមកនៅអាមេរិកក៏ដោយ គាត់នៅក្នុងពន្ធនាគារក៏ដោយ យើងទាំងពីរនាក់នេះដូចថា យើងយល់ចិត្តគ្នា ដូចថាដឹងចិត្តគ្នា ទោះបីនៅឆ្ងាយពីគ្នាមែនក៏ដូចថាយើងនៅជិតគ្នាដដែល។ ព្រោះហេតុអ្វីយើងសន្ទនាគ្នារាប់ឆ្នាំមកហើយអញ្ចឹងយើងយល់ ខ្ញុំយល់ពីទឹកចិត្ត នួន ជា។ ហើយចំពោះ ខៀវ សំផន ខ្ញុំមិនដែលខ្ញុំមែនថាខ្ញុំគាំទ្រខ្មែរក្រហមណាមួយទេ អត់ទេ ព្រោះចំពោះខ្ញុំច្បាស់លាស់ណាស់ អ្នកណាខុស អ្នកឯងខុស អ្នកណាត្រូវ អ្នកឯងត្រូវ។ ដូច្នេះហើយជា[ជំហរនេះ]ហើយបាន នួន ជា គាត់គាំទ្រ គាត់និយាយការពិតឲ្យខ្ញុំ មិនមែនត្រឹមតែ នួន ជា ទេ មេដឹកនាំខ្មែរក្រហម ដែលរស់នៅលួចលាក់ដោយជា សម្ងាត់ មានអ្នកខ្លះរហូតដល់សម្លាប់កូនស្តេច អ្នកដែលសម្លាប់កូនស្តេច សីហនុំហាស រាល់ថ្ងៃនៅរស់នៅឡើយទេ ខ្ញុំស្គាល់ ខ្ញុំបានជួប នេះហើយបានខ្ញុំដឹងថា ហេតុអីបានជារបបនេះ ហេតុអីបានខ្ញុំនិយាយថាសាលក្រមតុលាការខ្មែរក្រហមដែលធ្វើនេះខ្ញុំថា មិនយុត្តិធម៌ មិនអាចធ្វើឲ្យខ្ញុំផ្សះផ្សាជាតិបានទេ អាំនេះចំពោះខ្ញុំផ្ទាល់។ ហើយចំពោះទោស ខៀវ សំផន វិញ លោក ខៀវ សំផន ខ្ញុំមិនមែនលំអៀងទៅ ខៀវ សំផន អីទេ ព្រោះខ្ញុំជិតដិតជាមួយលោក នួន ជា។ ប៉ុន្តែ ខៀវ សំផន ខ្ញុំទទួលស្គាល់ថាគាត់អត់មានអំណាចអីទាល់តែសោះ។ ការពិតគេតែងតាំងពល... តែងតាំង...នួន ជា គាត់និយាយជាមួយខ្ញុំគាត់ថា គាត់និង ប៉ុល ពត ពីរនាក់ណា មានតែពីរនាក់ទេ អត់មាន...។

សេង ៖ បាទ! អញ្ចឹងដល់ចំណុចហ្នឹងដែរ អញ្ចឹងលោកអាចបញ្ជាក់បន្ថែមទេនៅក្នុងរចនាសម្ព័ន្ធខ្មែរក្រហមហ្នឹង រវាង ប៉ុល ពត នួន ជា អៀង សារី ខៀវ សំផន សុន សេន តាម៉ុកអីហ្នឹង តើមេដឹកនាំមួយណាដែលមានសិទ្ធិទទួលព័ត៌មានទូទៅទាំងអស់នៅក្នុងរបបទាំងស្រុងហ្នឹងបាទ?

សម្បត្តិ ៖ ទេ! ជាទូទៅអ្វីៗក៏ដោយគឺមានតែលោក ប៉ុល ពត និងលោក នួន ជា ទេបាទ!ជាអ្នក ធ្វើសេចក្ដីសម្រេចចិត្ត បានន័យថា រៀបចំផែនការ អ្វីៗទាំងអស់សម្រាប់ក្នុងទូទាំងប្រទេសរួចហើយបានមានអ្នកថ្នាក់ក្រោមៗបានទទួលអី... ផែនការពីគាត់។ ប៉ុន្តែដោយសារដូចខ្ញុំនិយាយអញ្ចឹងថាអ្នកដែលនៅខាងក្រោមគាត់ហ្នឹងវា ខ្ញុំនិយាយទៅវាភាគច្រើនណាស់ទៅហើយដែលក្បត់ប្រឆាំងនឹង ប៉ុល ពត ជាសម្ងាត់ ប្រឆាំងនឹងប៉ុល ពត និង នួន ជា។ សំខាន់ជាងគេ គឺក្រុមនឹងគេផ្ដោតទៅលើ ប៉ុល ពត និង នួន ជា ទេដែលគេរកសម្លាប់ប៉ុល ពត និង នួន ជា ផ្ដួល ប៉ុល ពត និង នួន ជា។ វិធីដែលចង់ ផ្ដួល ប៉ុល ពត និង នួន ជា គឺគេធ្វើដោយវិធីសម្លាប់ ប៉ុល ពត និង នួន ជា ធ្វើមិនបាន។ អ្នកដែលរៀបចំរចនាសម្ព័ន្ធដើម្បីផែនការសម្លាប់ ប៉ុល ពត គាត់មិនមែនអ្នកចូលរួមទេ ប៉ុន្តែគាត់ជាដៃគូអ្នក ដែលចូលរួម គាត់នៅរស់នៅឡើយរាល់ថ្ងៃ គាត់សារភាពពីចំណុចដែលថា ក្រុមគាត់បានធ្វើអ្វីខ្លះចំពោះ នួន ជា និង ប៉ុល ពត។ អញ្ចឹងបានថា នេះជាប្រវត្តិសាស្ត្រខ្មែរយើងមួយ ដែលថាធ្វើឱ្យខ្មែរយើងរាប់លាននាក់មិនទាន់យល់នូវរបបនេះអញ្ចឹងហើយបានថា ឯកសារភាពយន្តខ្ញុំទីពីរនឹងធ្វើឱ្យបងប្អូនខ្មែរយើង ខ្ញុំជឿជាក់ថា បើមិនមែនមួយរយភាគរយក៏កៅសិបប្រាំបីភាគរយដែរអាចថាគាត់ទទួលយកបានហើយ ខ្ញុំជឿជាក់ថា ប្រសើរជាជាងសាលក្រមកាត់ទោសមួយជីវិត។

សេង ៖ អញ្ចឹងលោក សម្បត្តិ អាចបញ្ជាក់បានទេថា អ្នកដែលគាត់សុខចិត្តមកនិយាយជាមួយសម្បត្តិ លោក សម្បត្តិ ឯងនឹង ហេតុអ្វីបានជាគាត់មិនព្រមទៅនិយាយនៅតុលាការ? តើលោកអាចសង្ឃឹមថា ថ្ងៃណាមួយគាត់នឹងទៅនិយាយនៅតុលាការឬក៏ត្រូវប្រើនូវយន្តការណាផ្សេងទៀតដើម្បីឱ្យគាត់និយាយឱ្យបានដឹងជាទូទៅនោះបាទ?

សម្បត្តិ៖ ប្រសិនជាតុលាការហ្នឹងយុត្តិធម៌ តុលាការហ្នឹងប្រាកដជាឯករាជ្យ មិនលំអៀង ពួកគាត់នឹងទៅនិយាយ។ ពួកគាត់ចង់និយាយណាស់ ពួកគាត់ចង់និយាយ។ ប៉ុន្តែតុលាការក៏ដឹងដែរថា តុលាការនេះវាមិនមានឯករាជ្យទេ ព្រោះវាមានទាក់ទិនអ្នកនយោបាយ។ ភាគីម្ខាងចោទ នាំអ្នកនេះកាត់ទោសអ្នកនេះ ភាគីម្ខាងបដិសេធ។ អញ្ចឹងហើយគេមើលឃើញថាតុលាការហ្នឹងអី... មិនយុត្តិធម៌ទេ មិនមែនតែចំពោះ.... ព្រោះខ្ញុំជាអ្នកស្រាវជ្រាវ ខ្ញុំជាអ្នក

កាសែត អញ្ចឹងខ្ញុំដឹង ខ្ញុំដើរច្រើនណាស់ អញ្ចឹងខ្ញុំដឹងទឹកចិត្តប្រជាជនថាតើទឹកចិត្តពួកគេ គេចង់បានតុលាការរបៀបណា។ តុលាការនេះភាគតិចណាស់ដែលគេគាំទ្រ ដែលធ្វើឱ្យប្រជាជនគាំទ្រ ខ្ញុំប៉ាននិយាយអញ្ចឹង។

សេង ៖ បានន័យថាគាត់បារម្ភអំពីសុវត្ថិភាពរបស់ពួកគាត់មែនទេ ប៉ា?

សម្បត្តិ ៖ បាទគាត់... ពេលដែលគាត់និយាយហ៊ាស គាត់សួរខ្ញុំ គាត់ថាតើបើសិនជាខ្ញុំនិយាយ តើរឿងហ្នឹងសុវត្ថិភាពគាត់យ៉ាងម៉េច។ ខ្ញុំសួរគាត់ថាហេតុអី? ខ្ញុំដឹងហើយ ខ្ញុំដឹងថាព្រោះអី។ ប៉ុនខ្ញុំចង់ដឹងពីយោបល់គាត់ គាត់ឆ្លើយប្រាប់ខ្ញុំថា លោកដឹងថាអ្នកដឹកនាំនៅក្នុងរដ្ឋាភិបាលអ្នកណាទេ? ប៉ា! ខ្ញុំថាខ្ញុំដឹង។ អញ្ចឹងបើខ្ញុំនិយាយទៅគេមិនសម្លាប់ខ្ញុំ។ គាត់និយាយអញ្ចឹងបាទ។ បើសិនបើមានការធានាពិតប្រាកដថាធានាអាយុ សន្តិសុខរបស់ពួកគាត់ ពួកគាត់នឹងឡើងនិយាយ។

សេង ៖ បាទ! នេះជាការកាត់ទោសកំរិតដំបូងក្នុងសំណុំរឿង០០២ ដែលមានពីរវគ្គ។ ដូច្នេះតើលោកគិតថានៅវគ្គទី២ អាចនឹងមាន ដូចថាភាពងាយស្រួលច្រើនដោយសារភស្តុតាងមានភាពប្រត្យក្សដូចជាដែលកន្លែងធ្វើទារុណកម្ម លលាក្បាល និងសាក្សី ហើយអាចនឹងអឺ... អឺ... លោកអាចនឹងមានការសហការឬយ៉ាម៉េចជួយឱ្យអ្នកទាំងនោះចេញមកសារភាពតទៅទៀតទេបាទ?

សម្បត្តិ៖ បាទ! ខ្ញុំនិយាយទៅចំពោះដែលថាភស្តុតាងមានដូចជាឆ្អឹងលលាក្បាលស្អីក៏ដោយយកមកធ្វើជាភស្តុតាង ខ្ញុំថាប្រជាជនខ្មែរយើងមិនមែនស្លាប់តែប៉ុណ្ណឹងឯណា មិនមែននៅតែទួលស្លែងហ្នឹងតូចបំផុត។ បាទ! យើងយកទួលស្លែងតូចបំផុតយកមកធ្វើនេះ។ ណោះប្រជាជនស្លាប់នៅតាមភូមិភាគ នៅតាមតំបន់ភូមិ នោះច្រើនណាស់។ យើងត្រូវណែ ត្រូវអញ្ចឹងបានថា ធ្វើម៉េចឱ្យបានដឹងរឿងហ្នឹង ហ្នឹងហើយយើងត្រូវស្វែងរកការពិតឱ្យច្បាស់ពិតប្រាកដ។ ឧទាហរណ៍ដូចជាចំនុចមួយចោទ ហេតុអីបានខ្ញុំថាសាលក្រមតុលាការខ្មែរក្រហមមិនយុត្តិធម៌ ពួកគាត់រកការពិតមិនឃើញខ្ញុំ អឺ...ពួកគាត់រកការពិតមិនឃើញ។ ឧទាហរណ៍ដូចជាចំណុចមួយចោទពីលោក នួន ជា អំពីការសម្លាប់ទាហាន លន់ ណុល នៅទួលពោធិ៍ជ្រៃខេត្តពោធិ៍សាត់ ខុសស្រលះ ខុសស្រលះ ខ្ញុំ ខ្ញុំស្តាប់មើលតុលាការនិយាយកាត់ទោស នួន ជា ចំណុចហ្នឹងមួយ គឺថាអយុត្តិធម៌ចំពោះលោក នួន ជា ណាស់។ បើថាកាត់គាត់ កាត់ទោសគាត់ពីវិធីផ្សេងណាមួយទៀតខ្ញុំមិនថាទេ បើថាកាត់ទោសចំពោះការសម្លាប់ទាហានលន់ ណុល នៅទួលពោធិជ្រៃ ខេត្តពោធិ៍សាត់នេះគឺខុសស្រលះម៉ង។ ទៅចោទថាលោក នួន ជា ជាអ្នកបញ្ជា អ្នកអី។ តាមការពិតអ្នកដែលផ្តួចផ្តើមគំនិតទៅ

សម្លាប់ទាហានលន់ ណុល មិនមែន នួន ជា ទេ។ ជនដែលក្បត់នឹង នួន ជា ជនដែលក្បត់នឹង ប៉ុល ពត ដែលសម្លាប់ ហើយអ្នកដែលសម្លាប់ក៏នៅរស់។ ហ៊ីសៗ អញ្ចឹងហើយបានខ្ញុំដឹងពីការពិត។ ហើយអ្នកណាដែលផ្តួចផ្តើមគំនិតសម្លាប់ប្រជាជន ហើយខ្ញុំជឿបើមនុស្សច្រើនណាស់ដែលនៅក្នុងរដ្ឋាភិបាលដែលផ្តួចផ្តើមគំនិតសម្លាប់ប្រជាជន អ្នកអស់ណ្ហឹងនៅរស់។ បាទ! ហើយជនទាំងអស់នោះ ទាំងនៅក្នុងរដ្ឋាភិបាល ទាំងនៅក្រៅរដ្ឋាភិបាល រស់នៅដោយសេរី។ ផ្តួចផ្តើមគំនិតសម្លាប់ប្រជាជនហើយ ទៅដាក់ ចោទកំហុសទៅលើគេ។ ខ្ញុំមិនមែនថា ប៉ុល ពត និង នួន ជា ស្អាតស្អំមួយរយភាគរយទេ មិនមែនទេ។ យើងចង់និយាយការពិត។

សេង ៖ អ្នកហ្នឹងនៅកន្លែងណាអឺ...សព្វថ្ងៃ លោក? នៅមានដំណែងទេបាទ?

សម្បត្តិ ៖ ខ្ញុំសុំទោសខ្ញុំមិនអាចនិយាយពីកន្លែងទេ។ ប៉ុន្តែគ្រាន់តែគាត់នៅស្រុកខ្មែរណ្ហឹងអែង រាល់ថ្ងៃនេះបាទ។

## ភាគទី II: ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៤

គឹម សេង ៖ មួយទៀតអឺ....លោក នួន ជា នឹង ត្រូវបានគេរកឃើញថាមាន ដូចថាមានការទទួលខុសត្រូវ ក្នុងការផ្លាស់ប្តូរប្រជាជនចេញពីទីក្រុង និងទីប្រជុំជនអឺហ្នឹង ហើយក្នុងការអឺ...... ដែលលោក ជួបសំភាសន៏ជាមួយ នួន ជា កន្លងមកហ្នឹង តើគាត់មានបានទទួលកំហុស នូវក្នុងការចេញគោលនយោបាយអោយមានការជំលៀសអឺ ប្រជាជនចេញទេបាទ?

សម្បត្តិ ៖ យឺ! អាំចំនុចនឹង គាត់ទទួល គាត់ទទួលខុសត្រូវ គាត់បាននិយាយប្រាប់ខ្ញុំអំពីការផែនការហ្នឹង ផែនការដែលគេធ្វើហ្នឹងណា ជំលៀសប្រជាជនចេញពីក្រុងភ្នំពេញ មិនមានតែទើបពេលរំដោះនឹងទេ គេ....ចង់មួយឆ្នាំជាងមុនណោះ គេសម្រេចមុន។ គេមើលពីផែនការថាពួក នួន ជា និង ប៉ុល ពត គាត់មើលប្រទេសជាតិ តើថាអនាគតត្រូវដើរទៅផ្លូវណា? ព្រោះប្រទេសជាតិត្រូវដើរទៅផ្លូវកសិកម្ម។ បាទ! ដូច្នោះដើម្បីទៅ ឆ្ពោះទៅកសិកម្មតើប្រជាជនរស់នៅក្នុងទីក្រុងបានរឺអត់? ប្រសិន.... ចឹងដីស្រែវានៅជាប់ជនបទ ចឹងអោយប្រជាជននៅក្នុងក្រុងយ៉ាងម៉ិច? ចឹងហើយបានគោលនយោបាយពួកគាត់ ដោយសារថាមានគោលនយោបាយហ្នឹងមួយផង ហើយទីពីរខ្លាចថាសង្គ្រាម ក្រែងលោវាមានការសង្គ្រាមផ្ទុះនៅក្នុងក្រុងភ្នំពេញផង គួបផ្សំគ្នាទៅទាំងពីរហ្នឹងបានពួកគាត់សំរេចចិត្តថាយក អោយប្រជាជនទៅរស់នៅតាមជនបទ។ ប៉ុន្តែអ្នកដែលរៀបចំធ្វើមិនបានល្អ។ នួន ជា គាត់ទទួលកំហុសអាំចំនុចហ្នឹង គាត់មិនមែនមានបំណងបង្ខំប្រជាពលរដ្ឋអឺ....របៀបនឹង

ទេ។ ប៉ុន្តែដោយសារថាអ្នកដែលថ្នាក់ដឹកនាំក្រោមៗហ្នឹងវាធ្វើបំផ្លើសហួស។ ពួកអ្នកដែលប្រឆាំង ប៉ុល ពត ខ្ញុំប្រាប់ទៅ ពួកអ្នកប្រឆាំង ប៉ុល ពតដែលចង់ផ្តួល ប៉ុល ពត មិនមែនទើបរំដោះ ថ្ងៃ១៧ មេសា៧៥ ហ្នឹងទេ។ យូរមកហើយ ពួកហ្នឹងគេចង់ផ្តួល ប៉ុល ពត និង នួន ជា វាយូរណាស់មកហើយ តាំងពីឆ្នាំ៦០ ពី៥០ ៦០ អឺ...ពេលកំពុងសង្គ្រាមគេៗ។ ទីក្រុងភ្នំពេញហ្នឹង ខ្ញុំគ្រាន់តែប្រាប់មួយ។ ពេលនោះណា មិនត្រូវបាន នួន ជា និង ប៉ុល ពត គ្រប់គ្រងទេ ពេលនោះ។ ត្រូវមានអ្នកផ្សេង ត្រូវមានអ្នកផ្សេងត្រូវគ្រប់គ្រងអឺ.... អឺ....កម្ពុជានៅពេលនោះ។ ប៉ុន្តែ ប៉ុល ពត និង នួន ជា គាត់ឆ្លាតវៀងវៃ ពេលនោះគាត់អាចទប់ទល់សភាពការណ៍បាន។ ចឹងខ្ញុំនិយាយប៉ុណ្ណឹង ខ្ញុំយល់ថាលោកគឹមសេងយល់ហើយ អំពីអឺ..... អ្វីដែលកើតឡើង ប៉ុន្តែវាច្រើនពេក។

គឹម សេង ៖ គោលនយោបាយមួយដែល..ដែលយើងឃើញ ឬក៏ជាការអនុវត្តមួយនៅក្នុងរបបខ្មែរក្រហមគឺការកំទេច ឬក៏លុបបំបាត់ប្រជាជនដែលគេមិនអាចកែប្រែបាន ហើយឈានទៅសំលាប់មនុស្សជិត ពីរលាននាក់ ដូចលោកអឺ.... លោកសម្បត្តិដឹងហើយ។ តើលោក នួន ជា ហ្នឹងគាត់មានបានលើកឡើងថារបបគាត់នឹងកែប្រែបានមនុស្សណាខ្លះ? ហើយយកអ្នកដែលកែប្រែហើយហ្នឹងអោយមកកាន់ដំណែងបានធំ បានអីតទៅទៀត ឬក៏ឃើញតែឡើងធំតែគ្នាគាត់ដដែលនឹងបាទ?

សម្បត្តិ ៖ មិនមែនអញ្ចឹងទេ បាទ! មិនមែនអញ្ចឹងទេ។ គឺថាគេអឺ.... នួន ជា និង ប៉ុល ពត គាត់ចង់ធ្វើអ្វីក៏ដោយដើម្បីអោយប្រជាជន នេះខ្ញុំនិយាយដោយភាពស្មោះត្រង់ នួន ជា ក៏ស្មោះត្រង់។ ខ្ញុំគោរព នួន ជា ដោយសារគាត់ជាមនុស្សស្មោះត្រង់ ស្រួលណាស់ចំពោះ នួន ជា ដើម្បីចោទប្រកាន់ទៅលើ ប៉ុល ពត ដាក់កំហុសទៅលើ ប៉ុល ពត។ ប៉ុន្តែ នួន ជា មិនមែនមនុស្សប្រភេទហ្នឹងទេ។ គាត់និយាយការពិត។ ចឹងខ្ញុំសូមនិយាយបញ្ជាក់អាពីរឿងផែនការដែលថាមានអីកើតឡើង។ គាត់ចង់អោយប្រជាជនមានហូបចុកគ្រប់គ្រាន់។ ផែនការត្រូវអោយហូបបង្អែមប៉ុន្មានថ្ងៃ បាយប៉ុន្មាន យ៉ាងម៉ិច រៀបចំផែនការនឹងអស់ហើយ។ ហេតុអ្វីបានប្រជាជនអឺ.. មិន អឺ.... មិនមានការហូបចុកគ្រប់គ្រាន់? ហើយរហូតអឺ... ដូចថាមិនមែនថាលោក នួន ជាហ្នឹងគាត់អប់រំចង់អោយថា មានតែគ្នាគាត់ចេះតែឡើងធំ ដូចថាសំនួរសួរមិញ មែនទេ។ ប្រសិនបើសិនជាប្រភេទហ្នឹងមែន ខ្ញុំប្រៀបធៀបចំនុចនេះមួយចុះ តើកូន នួន ជា ដែលគាត់មាន កូន នួន ជា ដែលធ្វើអ្នកធំមួយទេ? ពេលនោះកូន នួន ជា ធំៗអស់ហើយ។ តើកូន នួន ជា កូនប្រុស កូនស្រី ក្រមុំ កំលោះ អស់ហើយ ពេលសម័យដែលកំពុងគ្រប់គ្រងអំណាច។ តើគាត់មានតែងតាំងកូនគាត់ធ្វើជាអឺ.... មេកងពល ឬមិន

បាច់ដល់មេកងពលទេ ត្រឹមប្រធានវរសេនាតូច វរសេនាធំឬក៏មេក្រុម អត់ផងហ្នឹង។ បាទសូម្បីតែកូនគាត់ក៏ធ្វើការដូចពួកខ្ញុំដែរ។ បាទនេះជា ចឹងបានថា មិចធ្វើមិចបានថា នួន ជា គាត់ទៅមានគំនិតផ្តួចផ្តើមអី.... តែងតាំងមនុស្សតែគ្នាគាត់អត់មានទេ។ ព្រោះហេតុ មូលហេតុគឺវាមានអញ្ចឹងដែលខ្ញុំលើក។

គឹម សេង ៖ បាទ! លោកសម្បត្តិអី.... បញ្ជាក់មុននេះតិចគឺថាលោកនឹងចេញខ្សែភាពយន្ត ឯកសារទីពីរស្តីពីរបបខ្មែរក្រហមហ្នឹង តើអាចនែ៎ នឹងចេញនៅពេលណា? ហើយផ្តោតលើបញ្ហាអ្វីខ្លះ? អាចបញ្ជាក់តិចអោយបានដឹងទេបាទ។

សម្បត្តិ ៖ ឯកសារភាពយន្តខ្ញុំទីពីរនឹងគឺបញ្ជាក់អំពីការបង្ហាញអំពីជម្លោះ ដែលគេហៅថាសង្គ្រាមស៊ីវិលសម្ងាត់នៅក្នុងរបបខ្មែរក្រហម ហៅថាជម្លោះផ្នែកនយោបាយនៅក្នុងរបបខ្មែរក្រហម។ ហើយនឹងបង្ហាញអំពីអ្វីនៅពីខាងក្រោយការកាប់សម្លាប់នោះ។ ព្រោះឯកសារភាពយន្តខ្ញុំទីមួយគ្រាន់តែនិយាយជនដៃដល់ គាត់និយាយថា គាត់សម្លាប់ប្រជាជន គាត់សម្លាប់ចេះៗៗ។ ប៉ុន្តែអាក្រោយពីការ អាក្រោយដែលក្រោយការសម្លាប់ហ្នឹងហ្មេះ តើវាមានអ្នកណានៅពីរក្រោយការកាប់សម្លាប់? ចឹងឯកសារភាពយន្តខ្ញុំទីពីរ វានឹងបង្ហាញថា ហេតុអី? អ្នកណានៅពីក្រោយខ្នងការកាប់សម្លាប់នេះ? ចឹងបើសិនយើងស៊ីជម្រៅណា។ ការដែលទទួលខុសត្រូវរបបខ្មែរក្រហមនេះមិនមែនតែត្រឹមស្រុកខ្មែរយើងទេ ដែលត្រូវទទួលខុសត្រូវ។ មានប្រទេសខ្លះដែលត្រូវទទួលខុសត្រូវដូចខ្មែរក្រហមដែរក្នុងការអី.... ការស្លាប់របស់ប្រជាជនខ្មែរនេះ។

គឹម សេង ៖ បាទ! ចឹងគឺអី....គឺផ្អែកទៅលើតែការបកស្រាយរបស់លោក នួន ជា ម្នាក់ឯង ដែលលោកថាឃើញសម្លាប់អីហ្នឹង? ឬក៏លោកមានការសំភាសន៍ជាមួយអ្នកដែលដៃដល់មួយចំនួនទៀត ឬក៏អ្នកដែលនៅពីក្រោយនៃការចេញគោលនយោបាយ ឬក៏អ្នកដែលធ្វើអោយខូចគោលនយោបាយនឹងដែរទេបាទ?

សម្បត្តិ ៖ ខ្ញុំនិយាយពីរឿងលោក នួន ជា។ ពេលដែលខ្ញុំសំភាសន៍គាត់ គាត់មិនដែលណែនាំខ្ញុំទៅស្គាល់កម្មាភិបាលណាមួយទេ។ នេះជាជំហរ នួន ជា។ មិនមែនដូចអ្នកខ្លះ។ គាត់និយាយជាមួយខ្ញុំថាក្មួយបើសិនជាខ្ញុំណែនាំក្មួយអោយទៅស្គាល់កម្មាភិបាលណា ទៅសំភាសន៍។ បានន័យថា គេ អ្នកហ្នឹងគេគាំទ្រខ្ញុំណា។ នេះជាជំហរ នួន ជា គាត់និយាយច្បាស់ គាត់ថាក្មួយត្រូវរកការពិត រកដោយខ្លួនឯង។ ហ្នឹងបានខ្ញុំគោរព នួន ជា។ ខ្ញុំថានេះជាបុរស គេថាបុរសពិត មិនមែនបុរសក្លែងក្លាយទេ។ បុរសខ្លះក្លែងក្លាយគ្រាន់តែថា ពេលមានអំណាច

សប្បាយទាំងអស់គ្នា ពេលអស់អំណាចទៅចោទប្រកាន់គ្នាទៅវិញទៅមក។ នួន ជា គាត់មិនមែនមនុស្សប្រភេទហ្នឹងទេណ៎ា។ ប៉ា! ខុសគេបាទ។ ហ្នឹងហើយបានថាការអ្វីដែល នួន ជា និយាយប្រាប់ខ្ញុំ ខ្ញុំមិនមែនជឿគាត់មួយរយភាគរយទេ ឬក៏ខ្ញុំជឿដប់ភាគរយ ក៏ខ្ញុំមិនទាន់ជឿគាត់ដែរពេលហ្នឹងនោះ។ ពេលដែលគាត់និយាយប្រាប់ខ្ញុំ ខ្ញុំអត់ទាន់ទេ ព្រោះខ្ញុំគ្រាន់តែថត គាត់និយាយក៏ខ្ញុំអត់ចាប់អារម្មណ៍ថា ខ្ញុំជឿទេ។ ទាល់តែខ្ញុំ.. ដឹងជាសំណាងអីខ្ញុំចេះតែស្រាវជ្រាវៗទៅ ខ្ញុំជួបទាំងប្រធាន អ្នកគ្រប់គ្រងពន្ធនាគារ ក្រុមចារកម្ម បានន័យថាក្រុមស៊ើបអង្កេត រឿងកាប់សម្លាប់មនុស្ស អីហ្នុង ។ ហើយនឹងជនដែដល់ អ្នកដែលអឺ.... រៀបចំផែនការសម្លាប់ប្រជាជន។ ខ្ញុំជួបអ្នកទាំងអស់ហ្នឹងណា គាត់ប្រាប់ខ្ញុំពីផែនការទាំងអស់ហ្នឹងមកបានថាឱ អ្វីដែល នួន ជា និយាយមកការពិត។ ច្រើនចំនុចណាស់ដែល នួន ជា និយាយប្រាប់ខ្ញុំ ពេលនោះខ្ញុំអត់ជឿ នួន ជា ទេ។ គាត់ ដូចនិយាយឧទាហរណ៍មួយសម្លាប់ទាហាន លន់ ណុល អឺ.... សម្លាប់អឺ....ទាហានលន់ ណុល ហ្នឹងប៉ៃលុត ពួកប៉ៃលុត ពួកបើកយន្តហោះអឺ....លន់ ណុល ដែលគេ ទ័ពពួកនឹងដែលគេបញ្ជូនពីអឺ.... ពីប្រទេសថៃមកស្រុកខ្មែរ។ ពេលហ្នឹង នួន ជា គាត់ ប៉ុល ពត បានបញ្ជាអោយទទួលពួកគាត់ត្រឡប់វិញ ព្រោះថៃ រដ្ឋាភិបាលថៃ គេបញ្ជូនពួកគេមក។ ចឹងថាយើងត្រូវយកពួកគេមកអោយនៅរស់ក្នុងស្រុកយើងដើម្បីបានអឺ...សុខសប្បាយដូចគេដូចឯង។ ពេលនោះគឺថាមានកម្មាភិបាលម្នាក់ថ្នាក់ខ្ពស់បញ្ជាអោយសម្លាប់ពួកទាហានប៉ៃលុត។ អ្នកណាទៅជឿ នួន ជា? ខ្ញុំក៏មិនជឿគាត់ដែរពេលដែលគាត់និយាយពេលនោះ។ ប៉ុន្តែខ្ញុំមានខ្សែអាត់ខ្ញុំរួចអស់ហើយ ខ្ញុំចេះតែទុករាប់ឆ្នាំទៅ អ្វីដែលគាត់និយាយខ្ញុំអត់ជឿទេ។ ថ្ងៃមួយខ្ញុំទៅជួបប្រធានគុក ខ្ញុំទៅជួបកម្មាភិបាលផ្សេងៗដែលទទួលខុសត្រូវ ដែលសម្លាប់ពួកប៉ៃលុតហ្នឹង។ ខ្ញុំកុំសួរថាតើអ្នកណាដែលបញ្ជាអោយសំលាប់ប៉ៃលុត? គាត់ប្រាប់ខ្ញុំមកមិនមែន នួន ជា ប៉ុល ពត ណា។ អ្នកផ្សេងអ្នកបញ្ជា ជាសម្ងាត់។ ចឹងហើយបានខ្ញុំនិយាយថាអូអ្វីដែល នួន ជា និយាយនេះជាការពិត។ ចឹងបានថា នួន ជាគាត់និយាយអីអត់បំផ្លើសមួយមាត់ទេ។ បើខុសវិញខុសតែថ្ងៃទីបាទ! ឆ្នាំតែប៉ុនណ្ហឹងទេ។

គឹម សេង ៖ ដូច្នេះអឺ....ប៉ា! នៅចុងបញ្ចប់នេះ តើលោកចង់ឃើញតុលាការខ្មែរក្រហម នាពេលបច្ចុប្បន្ននេះបន្សល់នៅគេហៅថាស្នាដៃ ឬក៏កេរតំណែលយ៉ាងមិចខ្លះដល់ប្រទេសកម្ពុជា ហើយនិងក្មេងជំនាន់ក្រោយនោះបាទ?

សម្បត្តិ ៖ ខ្ញុំចង់បានការស្រាវជ្រាវដើម្បីផ្សះផ្សារជាតិ។ ប៉ុន្តែបើថាតុលាការវិញខ្ញុំសូមចង់អោយតុលាការហ្នឹងធ្វើអោយ មុនវិនិច្ឆ័យជនណាមួយក៏ដោយ លោក នួន ជា ក៏ដោយ លោក

ខៀវ សំផន ត្រូវធ្វើការស្រាវជ្រាវអោយម៉ត់ចត់សិន ចាំធ្វើការកាត់ទោស។ ហើយការកាត់ទោសត្រូវអោយមានទូលំទូលាយ។ បាទ កុំអោយយកមនុស្សតែបី បួននាក់ ពីរបីនាក់មក។ ចាំ! ត្រូវយកស្រាវជ្រាវ បានថាកំរិតណាក៏ដោយ នៅក្នុងរដ្ឋាភិបាលក៏ដោយ អ្នកណាក៏ដោយ ត្រូវតែហៅមកសួរចំលើយ អាហ្នឹងការពិតនឹងចេញហើយ។ មួយរយភាគរយនឹងចេញ។ ខ្ញុំជឿ។ ប្រសិនបើជាតុលាការមានអំណាចកោះហៅអ្នកណាក៏ដោយ ខ្ញុំជឿជាក់ថាជនដែលគេបានប្រព្រឹត្ត អ្នកដែលគេដឹងរឿងការពិត គេនឹងនិយាយហើយ។ មានណាស់ មានមនុស្សច្រើនណាស់ដែលគេចង់និយាយ។ ប៉ុន្តែគេឃើញតុលាការចឹង គេទៅនិយាយធ្វើស្អីបាទ។ ព្រោះវាអត់ទៅ ដើម្បីអត់ផលប្រយោជន៍។ ចឹងបានថាខ្ញុំសូមថាអោយតុលាការធ្វើមិច អោយមានអី....ការស្រាវជ្រាវកុំអោយចាំរាប់លេខមួយ លេខពីរ លេខបី អីមិនបាច់រាប់ទេបាទ។ ហៅមក ធ្វើមក ឋានៈណាក៏ដោយមិនបាច់ដាក់លេខទេ បាទ។ ហៅយកមកកាត់ទោសសិន ស្រាវជ្រាវអោយអស់សិន ស៊ីមកាត់ទោស។ ហើយអានេះមិនទាន់ស្រាវជ្រាវអស់ផងលែងកាត់ក្បាលម៉ាស៊ីន។ មុនដំបូងកាត់ ឌុច បាទ។ ពេលដែលគេកាត់ ឌុច ហើយទៅកាត់ក្បាលម៉ាស៊ីន។ ហើយចុះអាកន្ទុយ? ហើយអាកណ្តាលមិនដឹងនៅឯណា? ហើយចឹងតើការពិតនៅឯណា? ចាំ!។ ខ្ញុំថាការកាត់នេះអត់មិនអាចអី....មិនអាចរកយុត្តិធម៌ជូនប្រជាជនទេ។ ចំពោះខ្ញុំផ្ទាល់ខ្ញុំថាមិនអាចអី.... មិនអាចយកអី....យុត្តិធម៌ រកយុត្តិធម៌សំរាប់ខ្លួនខ្ញុំផ្ទាល់និងគ្រួសារខ្ញុំទេ បាទ។ ការពិត អានេះនិយាយដោយភាពស្មោះត្រង់។

គឹម សេង ៖ សូមអរគុណលោក ថេត សម្បត្តិ ច្រើនបាទ ដែលបានផ្តល់បទសម្ភាសន៍ខ្លីដល់វីអូអេ បាទ! សូមជម្រាបលាលោកបាទ។

សម្បត្តិ ៖ បាទ! សូមជម្រាបលាបាទ។ អរគុណលោក គឹមសេង បាទ។

## III. ច្បាប់ជាធរមាន

### ក. ការទទួលយកភស្តុតាងថ្មីក្នុងដំណាក់កាលប្តឹងសាទុក្ខ

7. នៅក្នុងក្របខណ្ឌ អ.វ.ត.ក វិធាន ១០៤(១) និង ១០៨(៧) នៃវិធានផ្ទៃក្នុងកំណត់ទៅលើការទទួលយកភស្តុតាងថ្មីនៅក្នុងដំណាក់កាលប្តឹងសាទុក្ខ។ អនុលោមតាមវិធាន ១០៤(១) "អង្គជំនុំជម្រះតុលាការកំពូលខ្លួនឯង អាចបើកការពិនិត្យលើភស្តុតាង និងស្វែងរកភស្តុតាងថ្មី" ដើម្បីធ្វើការសម្រេចលើបណ្តឹងសាទុក្ខនេះ។ វិធាន ១០៨(៧) នៃវិធានផ្ទៃក្នុង ចែងត្រង់ផ្នែកពាក់ព័ន្ធថា៖

ភាគីអាចស្នើសុំបន្ថែមភស្តុតាងចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល យោងតាមវិធាន ៨៧(៣) បើសិនជាភស្តុតាងនោះមិនអាចរកបានក្នុងពេលសវនាការ ហើយដែលអាចជាកត្តាកំណត់នាំឱ្យឈានដល់ការធ្វើសេចក្តីសម្រេចនៅក្នុងសវនាការ។ សេចក្តីស្នើសុំបន្ថែមភស្តុតាងត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីទំនាក់ទំនងដោយផ្ទាល់រវាងភស្តុតាងបន្ថែមថ្មីនោះ ជាមួយនឹងសម្អាងហេតុជាក់លាក់ ដែលអង្គជំនុំជម្រះសាលាដំបូងបានលើក។

8. អង្គជំនុំជម្រះបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួននាពេលមុនក្នុងការទទួលយកភស្តុតាងថ្មីអនុលោមតាមវិធាន ១០៨(៧) នៃវិធានផ្ទៃក្នុង ទាក់ទងនឹងបណ្តឹងសាទុក្ខ ដែលបានប្តឹងប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០១[14]។

## IV. ឧឡារិករណ៍

### ក. សំណើសុំនេះគួរធ្វើចំណាត់ប្រភេទជាឯកសារសាធារណៈ

9. ទោះបីជាសំណើសុំនេះយោងទៅបុគ្គលទាំងឡាយដែលអាចជាសាក្សីសក្តានុពលនៅក្នុងសំណុំរឿង ០០២/០២ និងត្រូវបានផ្តល់ឈ្មោះរហស្សនាមឱ្យហើយក៏ដោយ ក៏ក្រុមមេធាវីការពារក្តីកត់សម្គាល់ឃើញថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងអ៊ីមែលរបស់ Lemkin ត្រូវបានដាក់ជូនជាសាធារណៈដោយពុំមានការកោសលុប ឬប្រើប្រាស់ឈ្មោះរហស្សនាមនោះទេ[15]។ ព័ត៌មានដែលមាននៅក្នុងនោះគឺជាព័ត៌មានជាន់គ្នានឹងសំណើសុំនាពេលមុនរបស់ក្រុមមេធាវីការពារក្តី ឬដកចេញពីសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់បុគ្គលទាំងនេះផ្ទាល់។ អាស្រ័យហេតុនេះ គ្មានផលប្រយោជន៍អ្វីបន្ថែមត្រូវរក្សាការសម្ងាត់នោះទេ។

### ខ. សំណើសុំភស្តុតាងបន្ថែមអាចទទួលយកបាន

10. វិធាន ១០៨(៧) នៃវិធានផ្ទៃក្នុង ចែងយ៉ាងច្បាស់អំពីសំណើសុំភស្តុតាងបន្ថែមនៅចំពោះមុខអង្គ ជំនុំជម្រះតុលាការកំពូល ក្នុងករណីភស្តុតាងនេះ "ពុំអាចរកបាននៅមុនពេលជំនុំជម្រះ"។

---

[14] សំណុំរឿង ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង កាំង ហ្គេកអ៊ាវ* ឯកសារ F2/5/1 "សេចក្តីសម្រេចលើសំណើបន្ថែមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ សុំដាក់ភស្តុតាងបន្ថែម" ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១១ ERN 00657389-00657391។ សំណុំរឿង ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង កាំង ហ្គេកអ៊ាវ* ឯកសារ F2/4 "សេចក្តីសម្រេចលើសំណើរបស់សហមេធាវីការពារក្តីជនជាប់ចោទ និងតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ ២ និង ៣ សុំដាក់ភស្តុតាងបន្ថែម" ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១១ ERN 00656514-00656517។

[15] ឯកសារ E294/1 "សេចក្តីសម្រេចលើសំណើរបស់ នួន ជា ស្នើសុំឱ្យទទួលយកភស្តុតាងថ្មី ឱ្យចាប់ផ្តើមការស៊ើបអង្កេត និងឱ្យ កោះហៅលោក Rob Lemkin"។

11. កិច្ចសម្ភាសន៍នេះត្រូវបានផ្ដល់ជូននៅក្នុងខែ សីហា ឆ្នាំ ២០១៤ ក្រោយពេលអង្គជំនុំជម្រះសាលាដំបូងចេញសាលក្រមលើសំណុំរឿង ០០២/០១។ ក្រុមមេធាវីការពារក្ដីពុំបានដឹងអំពីអង្គហេតុពាក់ព័ន្ធ ដែលរួមមានការពិពណ៌នារបស់ ថេត សម្បត្តិ អំពីសម្ភារ/ឯកសារដែលគាត់មាន នៅមុនពេលសម្ភាសន៍នោះទេ។ ដោយហេតុថាឯកសារនេះពុំមានអត្ថិភាពកាលពីពេលមុន ឯកសារនេះ "ពុំអាចរកបាននៅក្នុងពេលជំនុំជម្រះឡើយ"។

12. ទោះបីជាពុំមានលក្ខខណ្ឌកំណត់ពេលវេលានៅក្នុងវិធាន ១០៨(៧) នៃវិធានផ្ទៃក្នុងក៏ដោយ ក៏ក្រុមមេធាវីការពារក្ដីកត់សម្គាល់ឃើញថា យោងតាមហេតុផលខាងលើ សម្ភារ/ឯកសារទាំងនេះ ត្រូវបានដាក់បញ្ចូលជាភស្តុតាងឆាប់បំផុតតាមឱកាសដែលអាចធ្វើបាន។ លើសពីនេះទៀត ភាគីទាំងអស់មានពេលវេលាច្រើនដើម្បីអនុវត្តសិទ្ធិរបស់ពួកគេក្នុងការឆ្លើយតប[16]។

## គ. កិច្ចសម្ភាសន៍អាចជាកត្តាកំណត់សំខាន់មួយនៅក្នុងការចេញសេចក្ដីសម្រេចក្នុងពេលជំនុំជម្រះ

13. ក្រុមមេធាវីការពារក្ដីកត់សម្គាល់ឃើញថា ខ្លួនអាចមានលទ្ធភាពបង្ហាញពេញលេញអំពីសារៈសំខាន់នៃកិច្ចសម្ភាសន៍នេះចំពោះសេចក្ដីសម្រេចនានាដែលបានធ្វើឡើងក្នុងពេលជំនុំជម្រះ នៅក្នុងបណ្ដឹងសាទុក្ខមួយផ្នែកប្រឆាំងនឹងសាលក្រមចុងក្រោយ។ ជាការប្រុងប្រយ័ត្ន ក្រុមមេធាវីការពារក្ដីដាក់សំណើសុំនេះ ដើម្បីធានាថា គ្មានភាពចម្រូងចម្រាស់កើតឡើងពាក់ព័ន្ធនឹងពេលវេលានោះទេ។ ក្រុមមេធាវីការពារក្ដីស្នើថា សារៈសំខាន់នៃកិច្ចសម្ភាសន៍នេះមានភាពច្បាស់លាស់ណាស់ ដោយលក្ខខណ្ឌតម្រូវផ្សេងៗក្នុងវិធាន ១០៨(៧) ត្រូវបានបំពេញ ផ្អែកទៅលើទឡ្ហីករណ៍សង្ខេបដែលត្រូវបានបង្ហាញនៅក្នុងសំណើនេះ។ ទោះបីជាយ៉ាងនេះក្ដី ប្រសិនបើអង្គជំនុំជម្រះសន្និដ្ឋានខុសពីនេះ ឬសម្រេចថា សំណើសុំនេះ ល្អបំផុត ត្រូវធ្វើរួមគ្នាជាមួយនឹងសារណាបណ្ដឹងសាទុក្ខនោះ ក្រុមមេធាវីការពារក្ដីសូមរក្សាសិទ្ធិលើកសំណើសុំនេះជាថ្មីម្ដងទៀតនៅក្នុងពេលនោះតែម្ដង។

14. សាលក្រមសំណុំរឿង ០០២/០១ បានធ្វើសេចក្ដីសន្និដ្ឋានទូទៅជាច្រើនទាក់ទងនឹងឋានានុក្រមនៃរចនាសម្ព័ន្ធរបស់បក្សកុម្មុយនីស្តកម្ពុជា ការពឹងផ្អែករបស់កម្មាភិបាលថ្នាក់ទាបចំពោះមជ្ឈិមបក្ស និងការទទួលខុសត្រូវរបស់មជ្ឈិមបក្សចំពោះការចោទប្រកាន់អំពីការកាប់សម្លាប់អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃ[17]។ កិច្ចសម្ភាសន៍ជាមួយនឹង ថេត សម្បត្តិ ដែលបានសម្ភាសន៍

---

[16] ឯកសារ E189/3/1/8 "សេចក្ដីសម្រេចលើ "បណ្ដឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីសំណើសុំឱ្យមានចំណាត់ការជាបន្ទាន់តាមវិធាន ៣៥" ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៣ កថាខណ្ឌ ១០-១១។

[17] ឧ. *សូមមើល* សាលក្រមសំណុំរឿង ០០២/០១ លេខយោងជើងទំព័រ ២០៣ ២១៧ ២២៣ ២៦៩ ២៨៦ ៨៥៩-៨៦០ ៩១៨-៩៣៩។

លម្អិតជាមួយនឹងសាក្សីដែលមានភាពស្ទាក់ស្ទើរក្នុងការមកផ្តល់សក្ខីកម្មជាមួយនឹងសហចៅក្រមស៊ើបអង្កេត រួមទាំងការស៊ើបអង្កេត "ជាច្រើនឆ្នាំ" ទៅលើហេតុការណ៍នៅទួលពោធិ៍ជ្រៃ" ពុំមានភាពស៊ីសង្វាក់ជាមួយនឹងសេចក្តីសន្និដ្ឋានទាំងអស់នេះទេ។ សាលក្រមសំណុំរឿង ០០២/០១ ដកស្រង់ស្នាដៃរបស់ ថេត សម្បត្តិ ម្តងហើយម្តងទៀត រួមទាំងការពិពណ៌នារបស់គាត់អំពីភស្តុតាងដែលគាត់ប្រមូលបាន និងការរៀបរាប់ដែលគាត់បានបង្ហាញនៅក្នុងខ្សែភាពយន្តរបស់គាត់ ដើម្បីគាំទ្រដល់សេចក្តីសន្និដ្ឋានទាក់ទងនឹងទួលពោធិ៍ជ្រៃ តួនាទីរបស់ នួន ជា និងរចនាសម្ព័ន្ធបក្សកុម្មុយនីស្តកម្ពុជា[18]។ កិច្ចសម្ភាសន៍នេះទំនងជាតម្រូវឱ្យអង្គជំនុំជម្រះវាយតម្លៃសាជាថ្មីលើភស្តុតាងនេះ ហេតុដូច្នេះវា"អាចជាកត្តាកំណត់សំខាន់មួយនៅក្នុងពេលជំនុំជម្រះ"។

15. លើសពីនេះទៀត កិច្ចសម្ភាសន៍នេះអាចជាកត្តាកំណត់សំខាន់ចំពោះសេចក្តីសម្រេចជាច្រើនផ្សេងទៀតក្នុងពេលជំនុំជម្រះ។ តាមសំអាងហេតុរបស់សហព្រះរាជអាជ្ញា និងអង្គជំនុំជម្រះសាលាដំបូងនៅពេលផ្ទៀងផ្ទាត់បញ្ជាក់ជាមួយនឹងការវាយតម្លៃរបស់ Rob Lemkin លើខ្សែភាពយន្តដែលមានចំណងជើងថា *មួយថ្ងៃនៅទួលពោធិ៍ជ្រៃ* កិច្ចសម្ភាសន៍នេះនឹងអាចបង្កើនភាពទុកចិត្តបានចំពោះអ៊ីមែលរបស់ Lemkin។ ដូច្នេះ ផលប្រយោជន៍របស់ នួន ជា ក្នុងការទទួលបានខ្សែភាពយន្តនេះដែលមិនទាន់មាននៅក្នុងសំណុំរឿងនៅឡើយ (រួមទាំងសិទ្ធិរបស់គាត់ក្នុងការការពារក្តី) នឹងកាន់តែមានទំហំធំធេងជាងមុន ដែលតម្រូវឱ្យអង្គជំនុំជម្រះសាលាដំបូងត្រូវវាយតម្លៃឡើងវិញទៅលើសេចក្តីសម្រេចរបស់ខ្លួនក្នុងការមិនបើកការស៊ើបអង្កេតនោះ។ បើទោះបីជាសម្ភារ/ឯកសារបង្ហាញថាពុំអាចទទួលបាននៅពេលនោះ វាកាន់តែរំលោភទៅលើសិទ្ធិរបស់ នួន ជា ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ថែមទៀត[19]។ ម្យ៉ាងវិញទៀត កិច្ចសម្ភាសន៍នេះនឹងបានបន្ថែមទម្ងន់ កាន់តែច្រើនទៅលើសេចក្តីសន្និដ្ឋានរបស់ក្រុមមេធាវីការពារក្តីដែលតម្រូវឱ្យធ្វើការវាយតម្លៃទៅលើខ្សែភាពយន្តដែលមានចំណងជើងថា *មួយថ្ងៃនៅទួលពោធិ៍ជ្រៃ* រួមជាមួយនឹងអ៊ីមែលរបស់ Lemkin ដែល

---

[18] សាលក្រមសំណុំរឿង ០០២/០១ លេខយោងជើងទំព័រ ៧១៩ ៩៧០ ១០៣៧ ២៤៩០ ២៥៩៧។

[19] *សូមមើលដូចជា* ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣៣៤ ("រហូតទល់នឹងការបិទកិច្ចពិភាក្សាដេញដោលជនជាប់ចោទ [...] អាចធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងជូនលិខិតស្នាមទាំងអស់ដែលខ្លួនយល់ឃើញថាមានប្រយោជន៍ដល់ការសំដែងឲ្យឃើញការពិត")។ ច្បាប់ អវតក មាត្រា ៣៥ថ្មី ("នៅក្នុងការចោទប្រកាន់មកលើខ្លួនជនជាប់ចោទអាចមានសិទ្ធិទទួលបាននូវការធានាជាអប្បបរមា [...] (ង) ពិនិត្យភស្តុតាងដាក់បន្ទុក និងទទួលបាននូវការចូលរួម និងការពិនិត្យភស្តុតាងដោះបន្ទុក ក្នុងលក្ខខណ្ឌដូចគ្នា និងភស្តុតាងដាក់បន្ទុកដែរ")។ ICCPR មាត្រា ១៤(៣)(ដូចគ្នា)។ ច្បាប់ ICC មាត្រា ៦៧(១)(ង)(ដូចគ្នា)។

ពន្យល់អំពីសារៈសំខាន់យ៉ាងខ្លាំងរបស់ខ្សែភាពយន្តនេះ ឬ បើមិនដូច្នោះទេ មិនពន្យល់អ្វីទាំងអស់[20]។ សាលក្រមសំណុំរឿង ០០២/០១ បានដកស្រង់យ៉ាងច្រើនពីខ្សែភាពយន្តដែលមានចំណងជើងថា *មួយថ្ងៃនៅទួលពោធិ៍ជ្រៃ* ដោយពុំបានយោងទៅអ៊ីមែលរបស់ Lemkin ឡើយ[21]។

16. កិច្ចសម្ភាសន៍នេះក៏បង្ហាញផងដែរថា ការពុំមានភស្តុតាងដោះបន្ទុកសំខាន់ៗនៅក្នុងកំណត់ត្រាកើតមានដោយសារតែការបំភិតបំភ័យ និងការជ្រៀតជ្រែករបស់រដ្ឋាភិបាល[22]។ ហេតុនេះ កិច្ចសម្ភាសន៍នេះបង្ហាញពីការពិតដែលផ្ទុយទៅនឹងការប្រឌិតជាយូរមកហើយនៅក្នុងសាលាក្តីនេះដែលថា ការជ្រៀតជ្រែកយ៉ាងសកម្ម និងយ៉ាងជាក់ស្តែងរបស់រដ្ឋាភិបាលដែលសមាសភាពមួយចំនួនជាអតីតបុគ្គលិកក្រោមបង្គាប់របស់ជនជាប់ចោទ ពុំមាន "ផលប៉ះពាល់ជាក់ស្តែង" ទៅលើលទ្ធភាពរបស់ក្រុមការពារក្តីក្នុងការបង្ហាញថា បុគ្គលិកក្រោមបង្គាប់ទាំងនោះបានធ្វើកិច្ចការដោយឯករាជ្យ ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មនានាដែលត្រូវបានចោទប្រកាន់[23]។ ដូច្នេះ វាអាចជាកត្តាកំណត់សំខាន់មួយចំពោះពាក្យសុំជាច្រើនរបស់ក្រុមមេធាវីការពារក្តីទាក់ទងនឹងសិទ្ធិទទួលបានការជំនុំជម្រះដោយសាលាក្តីឯករាជ្យ និងមិនលម្អៀងមួយ ដែលក្រុមមេធាវីការពារក្តីបានលើកឡើងបញ្ជាក់ម្តងហើយម្តងទៀតនៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល[24]។

## ឃ. អង្គជំនុំជម្រះតុលាការកំពូលត្រូវតែស្វែងរកការទទួលយកភស្តុតាងដោះបន្ទុក ដោយអនុលោមតាមវិធាន ១០៤(១)

17. អាស្រ័យដោយមូលហេតុដូចគ្នាដែលបញ្ជាក់នៅទីនេះ អង្គជំនុំជម្រះតុលាការកំពូល គប្បីប្រើឆន្ទានុសិទ្ធិរបស់ខ្លួនដើម្បីស្វែងរកភស្តុតាងថ្មី និងកោះហៅ Lemkin និង ថេត សម្បត្តិ ឲ្យផ្តល់សក្ខីកម្ម និងដើម្បីទទួលបានសម្ភារៈដូចដែលបានរៀបរាប់នៅក្នុងកិច្ចសម្ភាសន៍។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍មានអំណាចឥតស្ងៃចិត្តដើម្បីទទួលយកភស្តុតាងថ្មី បើការមិនទទួលយកភស្តុតាងនេះបង្កឲ្យមានការ

---

[20] ឯកសារ E295/6/3 "សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ នួន ជា នៅក្នុងសំណុំរឿង ០០២/០១" ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ៤៣៨។

[21] *សូមមើល* លេខយោងជើងទំព័រ ១១ *ដូចខាងលើ* ។

[22] *សូមមើល* កថាខណ្ឌ៦ *ដូចខាងលើ* ។

[23] ឯកសារ E189/3 "សេចក្តីសម្រេចលើសំណើសុំឲ្យមានវិធានការជាបន្ទាន់ដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង" ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ កថាខណ្ឌ ៩-១០។

[24] ឯកសារ E295/6/3 "សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ នួន ជា នៅក្នុងសំណុំរឿង ០០២/០១" ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ កថាខណ្ឌ ៨០-៨៦។

បាត់បង់យុត្តិធម៌[25]។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៅតុលាការ ICTR និង ICTY មានអំណាចកោះហៅសាក្សី និង បញ្ជាឱ្យពួកគេចូលខ្លួន[26]។ បើតាមចរិតលក្ខណៈនៃកិច្ចដំណើរការនីតិវិធីស៊ើបអង្កេតនៅ អវតក ភាសាដែលមានន័យទូលាយរបស់វិធាន១០៤(១) ផ្តល់អំណាចយ៉ាងទូលំទូលាយឱ្យអង្គជំនុំជម្រះតុលាការកំពូល ដើម្បីស្វែងរកភស្តុតាងបែបនេះ បើសិនជាខ្លួនយល់ថាសមស្រប។ ចំណាត់ការភ្លាមៗ គឺចាំចាច់នៅក្នុងករណីនេះ ដើម្បីធានាថា ភស្តុតាងដោះបន្ទុកសំខាន់ៗពីប្រភពដែលត្រូវបានចាត់ទុកថា អាចជឿទុកចិត្តទាំងដោយអង្គជំនុំជម្រះសាលាដំបូង និងសហព្រះរាជអាជ្ញា និងត្រូវបានពឹងផ្អែកយ៉ាងខ្លាំងដោយសាលក្រមនៅក្នុងករណី០០២/០១ គឺត្រូវបានបញ្ចូលក្នុងបញ្ជីនៃបណ្តឹងសាទុក្ខ។

## V. **សេចក្តីសន្និដ្ឋាន និងសំណើសុំ**

18. ហេតុដូច្នេះ ក្រុមមេធាវីការពារក្តី

ក. ស្នើសុំឱ្យទទួលយកខ្សែអាត់ថតសម្លេងនៃកិច្ចសម្ភាសន៍រវាង ថេត សម្បត្តិ ជាមួយនឹងវិទ្យុវីអូអេជាភាសាខ្មែរនៅថ្ងៃទី ១២ និងថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៤ ដែលមានលេខ ERN T01022159 និង T01022160 យកមកធ្វើជាភស្តុតាង និង

ខ. ស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលកោះហៅ ថេត សម្បត្តិ និង Lemkin ឱ្យមកផ្តល់សក្ខីកម្ម និងស្នើសុំឱ្យទទួលយកភស្តុតាងដែលយោងនៅក្នុងកិច្ចសម្ភាសន៍។

សហមេធាវីការពារក្តី នួន ជា

សុន អរុណ — Victor KOPPE

---

[25] រឿងក្តីរដ្ឋអាជ្ញា តទល់ Kupreskic, IT-95-16 សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍" ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០១ នៅកថាខណ្ឌ៥៨។

[26] វិធានស្តីពីភស្តុតាង និងនិតីវិធីរបស់តុលាការ ICTR និង ICTY វិធាន៩៨ និង១០៧។ រឿងក្តីរដ្ឋអាជ្ញា តទល់ Bogosora និងអ្នកផ្សេង ICTR-98-41-A "សេចក្តីសម្រេចលើញត្តិរបស់ Theoneste Bpgosora សុំឱ្យទទួលយកភស្តុតាងបន្ថែម ចុះថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ២០១១ នៅកថាខណ្ឌ១០។